# របាយការណ៍ប្រចាំខែ មេសា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តប៊ុរីរាំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប និងមានបុគ្គលិកសរុបចំនួន ៣៣ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ

- ថ្ងៃទី២៣ ខែមីនា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមប្រជុំដោះស្រាយបញ្ហាដីធ្លីនៅចំណុចអូរអំបិល ស្រុកអន្លង់វែង ក្រោមអធិបតីភាពឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្ត នៅសាលាស្រុកអន្លង់វែង
- ថ្ងៃទី២៤ ខែមីនា ប្រធានមន្ទីរ និងមន្ត្រី ២ រូប បានចូលរួមប្រជុំការផ្សព្វផ្សាយប្រកាសស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ថ្ងៃទី២៥ ខែមីនា មន្ត្រីរដ្ឋបាល បានចូលរួមពិធីផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី២៦ ខែមីនា ថ្នាក់ដឹកនាំមន្ទីរ បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលប្រចាំខែមីនា របស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី២៦ ខែមីនា មន្ត្រីគណនេយ្យ បានចូលរួមវគ្គផ្សព្វផ្សាយស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន និងប្រាក់ឧបត្ថម្ភបេសកកម្មសម្រាប់រដ្ឋបាលថ្នាក់ជាតិ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ថ្ងៃទី០២ ខែមេសា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយពី "យេនឌ័រ និងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិ ប្តី ប្រពន្ធ នៅសណ្ឋាគារឈើនប្រាក់កប ខេត្តឧត្តរមានជ័យ
- ថ្ងៃទី០២ ខែមេសា មន្ត្រីការិយាល័យរដ្ឋបាល ចូលរួមពិធីបុណ្យភូមិសាមគ្គី នៅភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ព្រមទាំងបានចូលរួមជាថវិកាចំនួន ១០ ម៉ឺនរៀល
- ថ្ងៃទី០៣ ខែមេសា ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីរដ្ឋបាល ចូលរួមអមដំណើរឯកឧត្តមអភិបាលខេត្តក្នុង

ពិធីចុះសាកសួរសុខទុក្ខកងកម្លាំងប្រដាប់អាវុធប្រចាំទិសទីបី ក្រោមអធិបតីភាពឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការពារជាតិ នៅទីលានប្រាសាទតាក្របី

- ថ្ងៃទី ២៨-មីនា ដល់ថ្ងៃទី ០៥-មេសា លោកប្រធានមន្ទីរ និងថ្នាក់ដឹកនាំមន្ទីរ ចូលរួមពិធីសំណេះសំណាលជាមួយមុខ សញ្ញាអតីតយុទ្ធ ក្រោមអធិបតីភាពឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ចំនួនបួនលើក នៅស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង(នៅមន្ទីរទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច)
- ថ្ងៃទី០៥ ខែមេសា លោកប្រធានមន្ទីរ ចូលរួមពិធីសូត្រមន្តប្រោះព្រំលើករាសីក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមែ សប្តស័កពុទ្ធសករាជ២៥៥៩ គ្រឹស្តសករាជ២០១៥ ក្រោមអធិបតីភាពឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលាប្រជុំសាលាខេត្ត
- ថ្ងៃទី០៧ ខែមេសា លោកប្រធានមន្ទីរ ចូលរួមចុះសួរសុខទុក្ខកងកម្លាំងឈរជើង ក្រោមអធិបតីភាពឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅប្រាសាទតាក្របីក្នុងស្រុកបន្ទាយអំពិល
- ថ្ងៃទី០៨ ខែមេសា ថ្នាក់ដឹកនាំមន្ទីរ បានចូលរួមការពិព័ណ៌កម្រងរូបភាពសមិទ្ធិផលអង្គការ Action Aids និងការប្រកាសបើកគម្រោងរបស់អង្គការកែប្រែសហគមន៍ក្នុងភាពជាដៃគូជាមួយ ActionAids នៅខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៨ ខែមេសា មន្ត្រីការិយាល័យរដ្ឋបាល ចូលរួមកិច្ចប្រជុំប្រចាំ ឆ្នាំ២០១៤-២០១៥ ជាមួយអង្គការមិនមែនរដ្ឋាភិបាល-ភាពជាដៃគូ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី០៨ ខែមេសា មន្ត្រីការិយាល័យរដ្ឋបាល និងគណនេយ្យ ចំនួន ០២ រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ (M&E) តាមប្រព័ន្ធកុំព្យូទ័រ នៅសណ្ឋាគារក្លស៊ី ខេត្តបាត់ដំបង
- ថ្ងៃទី០៩ ខែមេសា លោកប្រធានមន្ទីរ ចូលរួមប្រជុំសាមញ្ញលើកទី១១ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី២ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលប្រជុំធំសាលាខេត្ត និង
- ថ្ងៃទី១០ ខែមេសា មន្ត្រីរដ្ឋបាលចំនួន ០២ រូប ចូលរួមពិធីពិសារអាហារសាមគ្គី នៅទីធ្លាមុខសាលាខេត្តឧត្តរមានជ័យ ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

ចុះស្រង់ទិន្នន័យខ្សែផ្លូវចាស់បានប្រវែង ២៦ គីឡូម៉ែត្រ ចាប់ពីភូមិត្រពាំងអំពិលដល់ច្រកជប់គគី ស្រុកបន្ទាយអំពិល។

### ៣.២ ការងារថែទាំសុខភាពជនបទ

ថ្ងៃទី០៦-០៩ ខែមេសា មន្ត្រីបច្ចេកទេសចំនួន ០៣ រូប បានចុះសិក្សា និងវាយតម្លៃពីស្ថានភាពអនាម័យភូមិ បានចំនួន ២០ ភូមិ ០៤ ឃុំ និង ០២ ស្រុក មានអ្នកចូលរួម ចំនួន ៣៤៥ នាក់ ស្រ្តីចំនួន ១៦៨ នាក់។

**៣.៣ ការងារផ្គត់ផ្គង់ទឹកស្អាត**

ថ្ងៃទី ១៨-២៦ ខែមីនា ឆ្នាំ២០១៥ មន្ត្រីបច្ចេកទេសចំនួន បានសហការជាមួយអង្គការព្រា ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសសាងសង់បង្គន់អនាម័យ និងអាងត្រងទឹកភ្លៀង តាមគ្រួសារ ចំនួន ០៥ ភូមិ ក្នុងឃុំអំពិល ស្រុកបន្ទាយអំពិល និងបានចែកសម្ភារៈសាងសង់បង្គន់ចំនួន ១៤៧ បង្គន់។ បានចែកសម្ភារៈសាងសង់បង្គន់ នៅភូមិយាយទេព ឃុំបេង ស្រុកបន្ទាយអំពិលចំនួន ២៣ បង្គន់ និងភូមិគោករាំង និងនៅភូមិគោកត្រាង ឃុំជើងទៀន ស្រុកចុងកាល់ បានចែកសម្ភារៈសាងសង់បង្គន់ចំនួន ៧៥ បង្គន់ ។

**៤. ទិសដៅការងារបន្ត**

- រៀបចំប្រមូលទិន្នន័យអនាម័យភូមិ ចំនួន ៤៣ ភូមិ របស់កម្មវិធីអង្គការ Unicef
- ប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្រ្វីដេវចំនួន ៤៥អណ្តូង និងស្រះសហគមន៍ ០១កន្លែង (MRD)
- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវ ២១ អណ្តូង នៅស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ និងស្រុកបន្ទាយអំពិល
- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ ១៣ អណ្តូង នៅក្រុងសំរោង និងស្រុកបន្ទាយអំពិល
- ជួសជុលអណ្តូងស្នប់លេខ ៦ ចំនួន ១១ អណ្តូង នៅក្រុងសំរោង និង
- សាងសង់ស្រះសហគមន៍ ០១ កន្លែង នៅស្រុកបន្ទាយអំពិល ។